សំណុំរឿងរដ្ឋប្បវេណីលេខ ៨១៩ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៤ រឿងក្តីទាមទារឲ្យសងប្រាក់កម្ចី[1]

ដើមចោទ X

ចុងចម្លើយ Y

# ពាក្យស្នើសុំឲ្យពិនិត្យភស្តុតាង[9]

ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៤

គោរពជូន លោកចៅក្រម J នៃសាលាដំបូងរាជធានីភ្នំពេញ

មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ P

ទី១[2] ការស្នើសុំឲ្យសាកសួរសាមីភាគី[3]

១ អត្តសញ្ញាណរបស់សាមីដើមចោទ[4]

ឈ្មោះ ៖ X (នាំមក[5])

ភេទ ប្រុស កើតថ្ងៃ..... ខែ...... ឆ្នាំ......... មុខរបរពាណិជ្ជករ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ ០១០៤៦៦៨៨៤ / លិខិតឆ្លងដែនលេខ........... ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

២ គោលបំណងនៃការបញ្ជាក់[6]

(១) នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១២ ចុងចម្លើយបានសងប្រាក់មួយផ្នែកចំនួន ១,000ដុល្លារនៃកិច្ចសន្យាខ្ចីប្រាក់ទៅឲ្យដើមចោទ។

(២) នៅខែធ្នូ ឆ្នាំ២០១៣ ដើមចោទបានបង់ប្រាក់ចំនួន ៧,០០០ដុល្លារ ផ្អែកតាមកិច្ចសន្យាទិញលក់រថយន្តទៅឲ្យចុងចំលើយ។

៣ ចំណុចនៃការសាកសួរ[7]

ដូចបានការកត់ត្រានៅក្នុងចំណុចនៃការសាកសួរក្នុងឧបសម្ព័ន្ធ[8]

សូមអរគុណ

ឧបសម្ព័ន្ធ

## ចំណុចនៃការសាកសួរ ( សាមីដើមចោទ X )

១ តើទំនាក់ទំនងរវាងដើមចោទ X និងចុងចម្លើយ Y គឺជាអ្វី?

២ តើមូលហេតុអ្វីដែលនាំឲ្យដើមចោទផ្តល់ប្រាក់កម្ចីទៅឲ្យចុងចម្លើយ?

៣ បន្ទាប់ពីការកំណត់សងនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៨ បានកន្លងផុត មូលហេតុអ្វីដែលនាំឲ្យដើមចោទមិនបានដាស់តឿនចុងចម្លើយអំពីការសង?

៤ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១២ តើដើមចោទ X បានទទួលការទាក់ទងយ៉ាងដូចម្តេចពីចុងចម្លើយ Y ទើបបាននាំឲ្យជួបគ្នា?

៥ នៅថ្ងៃដដែល តើដើមចោទ X និងចុងចម្លើយ Yបានជួបគ្នានៅពេលណា ហើយនៅកន្លែងណា?

៦ នៅពេលនោះ តើចុងចម្លើយ Y បានពន្យល់អំពីប្រាក់១,០០០ដុល្លារដូចម្តេចទៅកាន់ដើមចោទ X?

៧ នៅពេលនោះ តើបង្កាន់ទទួលប្រាក់ និង ប្រគល់ប្រាក់ អ្នកណាជាអ្នករៀបចំ?

៨ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១២ តើដើមចោទ X បានចាត់ចែងដូចម្តេចចំពោះនំប្រហែល៥០០ប្រអប់ដែលខុសទ្រង់ទ្រាយពីរាល់ដងដែលបានទិញពីចុងចម្លើយ Y ?

៩ នៅពេលនោះ តើដើមចោទ X បាននិយាយអ្វីខ្លះជាមួយចុងចម្លើយ Y?

១០ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ តើកិច្ចសន្យាទិញលក់រថយន្តដែលបានបង្កើតឡើងរវាងដើមចោទ X និងចុងចម្លើយ Y មានខ្លឹមសារបែបណា?

១១ អំពីប្រាក់ថ្លៃរថយន្តនេះ តើដើមចោទ X បានបង់ប្រាក់នៃការលក់ទិញរថយន្តនេះឲ្យទៅចុងចម្លើយ Y នៅពេលណា? ទីកន្លែងណា ? របៀបណា?

១២ នៅពេលនោះ តើមូលហេតុអ្វីដែលនាំឲ្យដើមចោទ X និង ចុងចម្លើយ Y មិនបានធ្វើលិខិតទទួលប្រាក់ជាអាទិ៍?

១៣ ក្រោយពីចុះកិច្ចសន្យាទិញលក់រថយន្តនេះ តើដើមចោទបានទទួលការដាស់តឿនពីចុងចម្លើយអំពីប្រាក់បង់ថ្លៃរថយន្តសងដែរឬទេ?

១៤ ចំណុចទាំងឡាយផ្សេងទៀតដែលពាក់ព័ន្ធនឹងចំណុចទាំងនេះ។

សូមអរគុណ

( សេចក្តីពន្យល់ )

1. ត្រូវសរសេរអំពីព័ត៌មានដែលកំណត់អំពីរឿងក្តីដូចជា លេខសំណុំរឿង ឈ្មោះរបស់ដើមចោទ និង ចុងចម្លើយជាដើម។
2. ចំពោះការសាកសួរសាក្សី និង សាមីភាគីទាំងអស់ គម្បីធ្វើឡើងនៅក្នុងពាក្យសុំតាមតែអាចធ្វើបាន។ ឧទាហរណ៍ថា នៅក្នុងរឿងក្តីត្រូវធ្វើការសាកសួរសាក្សី W និង សាមីដើមចោទ X ដូច្នេះត្រូវសរសេរថា " ទី១ ការស្នើសុំឲ្យសាកសួរសាក្សី " "ទី២ ការស្នើសុំឲ្យសាកសួរសាមីភាគី" ហើយត្រូវសរសេរអំពី "អត្តសញ្ញាណរបស់សាក្សី (ឬក៏សាមីដើមចោទ)" "គោលបំណងនៃការបញ្ជាក់" "ចំណុចនៃការសាកសួរ" ទៅតាមចំណុចនីមួយផ្សេងពីគ្នា។
3. អំពីភស្តុតាងដែលបានស្នើសុំឲ្យពិនិត្យ ត្រូវសរសេរឲ្យច្បាស់លាស់ថាជាការសាកសួរសាក្សី ឬក៏ជាការសាកសួរសាមីភាគី។
4. នៅពេលដាក់ពាក្យស្នើសុំឲ្យសាកសួរសាក្សី ឬ សាមីភាគី ចាំបាច់ត្រូវសរសេរអំពីព័ត៌មានដែលកំណត់អំពីសាក្សី ឬ សាមីភាគី (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៣៨ កថាខណ្ឌទី១、មាត្រា១៤១ កថាខណ្ឌទី១・មាត្រា១៣៨ កថាខណ្ឌទី១) ។ ដោយឡែក ចំពោះព័ត៌មានដែលកំណត់អំពី សាក្សី ឬ សាមីភាគី យ៉ាងហោចណាស់ត្រូវតែសរសេរឈ្មោះរបស់គាត់ / នាង / ពួកគាត់ ឬ នាមករណ៍ និង អាសយដ្ឋាន (យោងតាមក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៣៨ កថាខណ្ឌទី៤ ចំណុច ក. )។
5. ដោយឡែកក្នុងករណីដែលធ្វើការកោះហៅសាក្សី ចាំបាច់ត្រូវអនុវត្តនីតិវិធីនៃការកោះហៅ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា ១៣៨ កថាខណ្ឌទី៣ និងទី៤ ) ហើយគប្បីសរសេរថា "នាំមក" ឬ "កោះហៅ" សាក្សី?
6. ភាគីដែលដាក់ពាក្យស្នើសុំឲ្យពិនិត្យភស្តុតាង ត្រូវតែសរសេរហើយកំណត់អំពីអង្គហេតុដែលត្រូវបញ្ជាក់ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១២៥ កថាខណ្ឌទី ១ )។
7. នៅពេលដាក់ស្នើសុំសាកសួរសាក្សី ឬ សាកសួរសាមីភាគី គឺត្រូវតែដាក់ជូនលិខិតដែលបានកត់ត្រាអំពីចំណុចនៃការសាកសួរ (មាត្រា១៣៨ កថាខណ្ឌទី២ មាត្រា១៤១ កថាខណ្ឌទី១ មាត្រា១៣៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
8. ចំណុចនៃការសាកសួរគួរតែដាក់ក្នុងឧបសម្ព័ន្ធដាច់ដោយឡែកពីគ្នាដោយសរសេរអំពីចំណុចនៃការសាកសួរសាក្សី ឬ ភាគី។ ។
9. ចំពោះការស្នើសុំសាកសួរសាក្សី ការសាកសួរភាគី គួរតែធ្វើឡើងនៅក្នុងការស្នើសុំឲ្យពិនិត្យភស្តុតាងដែលធ្វើឡើងតាមរយៈពាក្យស្នើសុំឲ្យពិនិត្យភស្តុតាងនេះ។